ខ្លឹមសារសង្ខេបសាលដីកាតុលាការកំពូលលេខ៦៥ (១៦ ខែមីនា ឆ្នាំ២០២០)

**ពាក្យគន្លឹះ៖** រំលោភលើទំនុកចិត្តពិសេស, មោឃកម្ម, សមត្ថកិច្ចតុលាការ

## ១. អង្គហេតុនិងខ្លឹមសារសម្រេច

ជនជាប់ចោទ បានចុះកិច្ចព្រមព្រៀងលក់ភាគហ៊ុន ហើយត្រូវបានផ្តល់សិទ្ធិជាអភិបាលក្រុមហ៊ុន ហើយតាមកិច្ចសន្យា គាត់ត្រូវបានហាមធ្វើសកម្មភាពមួយចំនួនមានលក្ខណៈប្រកួតប្រជែងនឹងអាជីវកម្មក្រុមហ៊ុន។ ក៏ប៉ុន្តែ គាត់បានលួចបើកក្រុមហ៊ុនថ្មីមួយទៀត ដោយកិបកេងយកប្រាក់ចំណូលពីក្រុមហ៊ុនដែលគាត់ជាអភិបាល។

អង្គហេតុនេះ ត្រូវបានចោទជាបទរំលោភលើទំនុកចិត្តពិសេសដោយអភិបាលនិងលួច តាមមាត្រា៣៥៣, ៣៥៦និង ៣៩៣នៃក្រមព្រហ្មទណ្ឌ។ មេធាវីការពារជនត្រូវចោទ បានដាក់ពាក្យសុំមោឃៈភាព ក៏ប៉ុន្តែត្រូវបានបដិសេធដោយសាលាឧទ្ធរណ៍ (សាលដីកាលេខ៦៨ ខែតុលា ឆ្នាំ២០១៩)។ មេធាវីជនត្រូវចោទបានប្តឹងសាទុក្ខមកតុលាការកំពូល។

### តុលាការកំពូល

តុលាការកំពូលបាន ឆ្លើយតបនឹងការអះអាងរបស់មេធាវីថា មិនមានយុត្តិធម៌ ដោយអះអាងថា៖ ...២. *ជាការមិនត្រឹមត្រូវទេ ពីព្រោះថា ក្នុងពាក្យបណ្តឹងសុំមោឃកម្មនីតិវិធីស៊ើបសួររបស់ចៅក្រមស៊ើបសួរសាលដំបូងរាជធានីភ្នំពេញ ដោយមូលហេតុនត្ថិភាពនៃសមត្ថកិច្ចដែនដីនោះ ត្រូវបានសភាស៊ើបសួរពិចារណាក្នុងសំអាងហេតុត្រង់ចំណុចទី៥នៃសាលដីកាថា"ផ្អែកតាមការពិភាក្សាដេញដោល និងតាមការពិនិត្យឯកសារពាក់ព័ន្ធឃើញថា តាមកិច្ចព្រមព្រៀងរបស់ភាគីដើមបណ្តឹងនិងជនត្រូវចោទ និងតាមឯកសារបង្ហាញព័ត៌មានលម្អិតរបស់ជនត្រូវចោទ និងតាមដីកាសម្រេចរក្សាការពារដែលឈ្មោះ...ប្តឹងសុំដីកាសម្រេច គឺបានប្រើប្រាស់អាសយដ្ឋាននៅរាជធានីភ្នំពេញប្រាកដមែន។ ហេតុដូច្នេះ ចៅក្រមស៊ើបសួរទទួលចាត់ការសំណុំរឿងក្តីនេះ ពុំមានលក្ខណៈផ្ទុយនឹងមាត្រា១២៣នៃក្រមនីតិវិធីព្រហ្មទណ្ឌឡើយ"*។

### សម្រេច

១. បដិសេធបណ្តឹងសាទុក្ខ...២. តម្កល់សាលដីកាលេខ៦៨...។

## ២. កំណត់សំគាល់

**ក.** មកដល់ថ្ងៃសវនាការនៃតុលាការកំពូល មានរយៈពេល៥ឆ្នាំ។

**ខ.** ក្នុងដំណើរនីតិវិធីក្តី ជនត្រូវចោទមានសិទ្ធិស្នើសុំមោឃកម្មទៅសភាស៊ើបសួរនៃសាលាឧទ្ធរណ៍ ពាក់ព័ន្ធសមត្ថកិច្ច ឬវិការៈនៃនីតិវិធីណាមួយ។ តាមខ្លឹមសារនៃសាលដីកានេះ ភាគីអាចប្តឹងទៅតុលាការកំពូល ប្រឆាំងសាលាដីកាសាលាឧទ្ធរណ៍ បដិសេធបណ្តឹងសុំមោឃកម្ម។

ខ្លឹមសារសង្ខេបសាលដីកា ពាក់ព័ន្ធនឹងបទរំលោភលើទំនុកចិត្តពិសេសដោយអភិបាល សូមមើល៖Measboralaws